# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៣២៧ ព្រទ/២០០១

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**លោកប្រធានតុលាការខេត្ត-ក្រុង**

**លោក ព្រះរាជអជ្ញាអមតុលាការខេត្ត-ក្រុង**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ</u>:** អំពីការឃុំខ្លួនពិរុទ្ធជនលើសថេរវេលាកំណត់នៃច្បាប់ ។

**<u>យោង</u>:** លិខិតលេខ១៧៩-០២គ.ស.ម.កចុះថ្ងៃទី០៣-០៩-០១ របស់គណៈកម្មាធិការការពារសិទ្ធិមនុស្សកម្ពុជា ។

ខ្ញុំសូមជម្រាបអស់លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ថា គណៈកម្មាធិការការពារសិទ្ធិមនុស្សកម្ពុជាបានសង្កេតឃើញថា បច្ចុប្បន្នមានពិរុទ្ធជនមួយចំនួនដែលកំពុងជាប់ឃុំជាបណ្ដោះអាសន្នលើសថេរវេលាកំណត់នៃច្បាប់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជានៅមិនទាន់បានទទួលការវិនិច្ឆ័យទោសនៅឡើយ គណៈកម្មាធិការនេះ បានសំណូមពរឱ្យក្រសួងយុត្តិធម៌ជួយជំរុញដល់តុលាការខេត្ត-ក្រុង ឱ្យលើកយកករណីឃុំខ្លួនពិរុទ្ធជនលើសថេរវេលានេះមកចាត់ការដាក់ជំនុំជម្រះឱ្យបានឆាប់ និងទប់ស្កាត់កុំឱ្យបាតុភាពនេះកើតមានបន្តទៀត ពាក់ព័ន្ធនឹងការឃុំខ្លួនលើសកំណត់ច្បាប់នេះ សេចក្ដីសម្រេចនៃសន្និបាតការងារយុត្តិធម៌ ឆ្នាំ២០០០ របស់ក្រសួងយុត្តិធម៌ចំណុច II ធំ អំពីបញ្ហារយៈពេលនៃការឃុំខ្លួនតាមច្បាប់កំណត់ បានកំណត់អំពីផែនការ និងវិធានការនេះសព្វគ្រប់អស់ហើយ ។

ដូច្នេះសូមលោកប្រធានតុលាការ លោកព្រះរាជអាជ្ញាចាត់វិធានការឱ្យមន្ត្រីក្រោមឱវាទ កំណត់ពេលវេលាសមស្របធ្វើយ៉ាងណាឱ្យស្ថាប័នអយ្យការ និងតុលាការសហការគ្នាល្អ ក្នុងការដោះស្រាយរឿងក្តី ជៀសវាងការឃុំខ្លួនជនត្រូវចោទលើសកំណត់ច្បាប់ លោកជួបការលំបាកមិនអាចដោះស្រាយបាន សូមរាយការណ៍ជូនក្រសួងយុត្តិធម៌ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាបន្ទាន់ មាត្រា៥៥ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

ទទួលបានសេចក្តីណែនាំនេះ សូមលោកប្រធានតុលាការ លោកព្រះរាជអាជ្ញាជួយផ្សព្វផ្សាយដល់មន្ត្រីក្រោមឱវាទឱ្យយកស្មារតីទទួលខុសត្រូវខ្ពស់ បំពេញតាមតួនាទីរៀងៗខ្លួនដែលច្បាប់ប្រគល់ឱ្យដោយគោរពថេរវេលាដែលមានកំណត់ក្នុងច្បាប់ ឬ សារាចរផ្សេងៗរបស់ក្រសួងជៀសវាងការចោទប្រកាន់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ។

សូមលោកប្រធានតុលាការ លោកព្រះរាជអាជ្ញាទទួលនូវការស្រលាញ់រាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០១

**រដ្ឋមន្ត្រី**

**នាង ស៊ីផុន**

<u>ចម្លងជូន</u>

- តុលាការកំពូល
- សាលាឧទ្ធរណ៍
- គណៈកម្មាធិការ ការពារសិទ្ធិមនុស្សកម្ពុជា

“ដើម្បីជ្រាប”